-ជួយរិះរកមធ្យោបាយផ្សេងៗ ដើម្បីជំរុញអោយមានការបង្កើតធនាគារពាណិជ្ជកម្មតាមខេត្ត ដែលអាចធ្វើប្រព័ន្ធ ហិរញ្ញវត្ថុអាចមានការងាយស្រួលក្នុងការផ្ញើ-ផ្ទេរមូលនិធិ គ្រប់គ្រងធនធានខ្លួនបាន និងជួយបង្កើតធនធានឥណទានសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ។

ឃ-រៀបចំកម្មវិធី និង ផែនការដើម្បីបង្កលទ្ធភាពងាយស្រួលក្នុងការគៀងគរ ជំនួយពី បរទេស សំរាប់តំរូវការឥណទាន ។

-កំណត់ទិសដៅ និង សំរបសំរួលជំនួយទ្វេភាគី និងពហុភាគីក្នុងវិស័យឥណទានជនបទ ។

**មាត្រា ៥ :** អង្គភាពបច្ចេកទេសរបស់ គជទាន មានភារកិច្ចដូចតទៅ :

-អនុវត្តការងារប្រចាំថ្ងៃរបស់ គជទាន

-រៀបចំរាល់សំណុំរឿងទាក់ទិននឹង គជទាន ដើម្បីដាក់ជូន គជទានពិនិត្យ និង អនុម័ត ។

-សំរបសំរួលការងារប្រតិបត្តិករទាំងអស់ ដែលប្រើប្រាស់ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ។

**មាត្រា ៦ :** នាយក ក៏ដូចជាអង្គភាពបច្ចេកទេសត្រូវបានតែងតាំងឡើងសំរាប់រយៈពេលគ្រប់គ្រាន់ ដើម្បីបំពេញអាណត្តិក្នុងការ អភិវឌ្ឍន៍ឥណទានជនបទតាមកម្មវិធីផ្តល់ជំនួយ ។

**មាត្រា ៧ :** រាល់អនុក្រឹត្យ និង សេចក្តីសំរេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** គជទាន និង រាល់ក្រសួង ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ៣១ អនក្រ
# ស្តីពីការបំពេញបន្ថែមក្នុងប្រតិទិនឈប់សំរាកការងារ
# របស់មន្ត្រីរាជការ និយោជិក កម្មករ ប្រចាំឆ្នាំ ១៩៩៥

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-តាមសំណើរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិ លេខ ៣២៥-៩៤ គបជអ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៤ ។

## សំរេច

**មាត្រា ១ :** បំពេញបន្ថែមលើអនុក្រឹត្យ លេខ ០៣ អនក្រ ចុះថ្ងៃទី ០៥-០១-៩៥ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៥ នូវប្រតិទិនឈប់សំរាកការងារ មួយថ្ងៃ គឺ ÷

-ថ្ងៃទី ២៤ កញ្ញា បុណ្យខួប ឡើងគ្រងរាជសម្បត្តិនៃព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ នៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ១៤ អនក្រ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com